KINGDOM OF CAMBODIA
Nation Religion King

# MEMORANDUM OF UNDERSTANDING

Between

The Ministry of Interior of the Kingdom of Cambodia

And

The Child Protection Unit of Cambodian Children's Fund

On

Contribution to humanitarian and criminal justice activities
For Juveniles in the Kingdom of Cambodia

2026-2029

## PREFACE

**Whereas -**

- The Ministry of Interior of the Kingdom of Cambodia expresses its support, as per this Memorandum of Understanding, to the Child Protection Unit (CPU) of the Cambodian Children's Fund to participate in humanitarian activities for social welfare and public interests through mutual cooperation.
- The Ministry of Interior of the Kingdom of Cambodia and the Child Protection Unit of the Cambodian Children's Fund acknowledge that there are several forms of crimes relating to human trafficking, online and offline child sexual abuse and exploitation and other crimes against women and children.
- Recognize that due to the complexity of these crimes; it may be necessary to use investigating techniques of specialists including secret intelligence agents, for the purpose of gathering evidence and intelligence to prosecute crimes related to human trafficking, sexual abuse, child exploitation, cybercrime and other crimes against children in line with the effective procedures of the Kingdom of Cambodia. The use of the secret intelligence agents is a successful and effective source used by law enforcement agencies around the world.
- To combat human trafficking, sexual abuse and all forms of exploitations against children and women, the Child Protection Unit of the Cambodian Children's Fund intends to work directly with: the Department of Anti-Trafficking and Juvenile Protection, the Department of Scientific and Technical Police, and the Criminal Investigation Department, the Anti-Cyber Crime Department, Anti-Drug Department of the General Commissariat of the National Police, the Ministry of Interior; by participating in the following direct humanitarian activities:

## Section 1
## Purpose

This Memorandum of Understanding aims to increase the cooperation between relevant units of the National Police of the Ministry of Interior and the Child Protection Unit of the Cambodian Children's Fund in contributing to: the collection and provision of information, intervention and rescue, coordination of child care after rescuing, and training of Cambodian National Police.

## Section 2
## Cooperative Activities:

### 1. Collection and Provision of Information

- The Child Protection Unit of the Cambodian Children's Fund cooperates with the Interior Ministry's General Commissariat of National Police to assist in providing investigative information and collecting evidence related to all forms of human trafficking, particularly women and children, ensuring all the collected evidences of crimes in violation of the laws of the Kingdom of Cambodia are provided to the relevant competent skilled units and cooperate for implementation in line with the skilled procedures. All procedures for intelligence collection shall be requested to the relevant skilled department of the National Police for approval prior to the commencement or implementation.
- Report and detailed information about crimes relating to all forms of human trafficking, especially child abuse must be submitted to the General Commissariat of

the National Police through the Anti-Human Trafficking and Juvenile Protection Police Department and the relevant departments.

- Location for initial identification and report about victims of all forms of human trafficking, especially child abuse must be submitted to the General Commissariat of the National Police through the Anti-Human Trafficking and Juvenile Protection Police Department and the relevant police departments.

2. **Intervention and Rescue**
   - The Child Protection Unit of the Cambodian Children's Fund must closely cooperate with the relevant skilled departments of the General Commissariat of the National Police of the Ministry of Interior, to intervene and rescue victims of human trafficking from the venues and situations of all forms of human trafficking, particularly child abuse and to ensure that the related perpetrators are arrested for court prosecution in accordance with the laws of the Kingdom of Cambodia.
   - Must cooperate with the competent officers to provide legal support and initial care services to the victims of all forms of human trafficking, especially child abuse.

3. **Post-Rescue Coordination**
   - The Child Protection Unit of the Cambodian Children's Fund must cooperate to help transport the victims from the incident scene to the secure and safe venues for further interview by the competent officer and then cooperate with the Capital-Provincial Department of Social Affairs, Veterans and Youth Rehabilitation (DoSAVY) under the guidance of the Memorandum of Understanding between the Child Protection Unit of the Cambodian Children's Fund to transport the victims from the police station to the aftercare shelter accredited by the Royal Government or to reintegrate the victims back to their community.
   - Must coordinate with other competent officers, including with the Capital-Provincial Department of Social Affairs, Veterans and Youth Rehabilitation to provide care to the victims in crisis, especially the victim minors after the immediate rescue.
   - The operation of all humanitarian acts to help child victims and children vulnerable to human trafficking must be done in line with its plan of actions and policies by firmly adhering to the cooperative principle in line with the laws of the Kingdom of Cambodia.

4. **Training of Cambodian National Police**
   - The Child Protection Unit of the Cambodian Children's Fund must cooperate with the relevant skilled department s of the General Commissariat of the National Police of the Ministry of Interior to deliver specialized trainings agreed by its technical working group, including the topics such as legal perspective on combatting human trafficking and sexual exploitation, work ethics of law enforcement officers, collection of criminal intelligence.

## Section 3
## Responsibilities of General Commissariat of National Police of the Ministry of Interior

- Allow the Child Protection Unit of the Cambodian Children's Fund (CPU) to cooperate and support the relevant units of the General Commissariat of the National Police in the secret intelligence investigation of human traffickers and persons involved in the exploitation of children, perpetrators involved in sexual abuse and child exploitations, perpetrators involved in cybercrime, other crimes

against children, and crimes committed by public officials who abuse their power over the victims. After receiving credible and reliable evidence from the Child Protection Unit of the Cambodian Children's Fund, the General Commissariat of the National Police immediately order further investigations in compliance with specialized procedures to suppress the crimes and arrest the suspects for court prosecution by law.

- Agree that the collection of information and evidences related to human trafficking, sexual exploitation, sexual abuse, all forms of child abuses and other crimes shall be in accordance with the laws of the Kingdom of Cambodia.
- Allow the General Commissariat of National Police to approve the project of Child Protection Unit of the Cambodian Children's Fund in support of specialized police training and capacity building of the National Police. All of these training projects shall be approved by the National Police General Commissariat of the Ministry of Interior in advance.

## Section 4

## Responsibilities of the Child Protection Unit of the Cambodian Children's Fund

- Comply with the laws and regulations of the Kingdom of Cambodia and do not allow its agents to participate or engage in any activity contrary to the law that endangers security, stability and social order, or any activity that may endanger national security, national unity, culture, tradition and customs of the people of Cambodia.
- Participate in only humanitarian activities permitted by the General Commissariat of National Police of the Ministry of Interior for social welfare and public interest only and avoid engaging in income generation and political activities that do not serve for the humanitarian purpose of the Child Protection Unit of the Cambodian Children's Fund as declared.
- Implement its activities and programs in the Kingdom of Cambodia within the limits of its human resources and funds and ensure that all evidence of violations of the laws of the Kingdom of Cambodia that is found and collected is provided to the relevant specialized units that are competent for further actions.
- All secret intelligence investigation procedures will be submitted to the Anti-Human Trafficking and Juvenile Protection Police Department and the relevant skilled departments for approval between the parties prior to its commencement or implementation.
- Not be allowed to participate in any activities related to the pursuit of interests and any political activity that may affect the security, stability and social order or any other activity that may endanger the national security, national unity, culture and traditions of the people of Cambodia.
- Develop semi-annual and annual reports on achievements as well as challenges encountered to the General Commissariat of National Police, the Ministry of Interior, for information and solutions.
- Notify the General Commissariat of National Police, the Ministry of Interior, in writing of any changes regarding the address, the assigned representative and project manager.
- A summary of the actual humanitarian projects and activities of the Child Protection Unit of the Cambodian Children's Fund in collaboration with the General Commissariat of National Police, the Ministry of Interior, shall be implemented as detailed in Annexes (1) and (2).

## Annex 1
## Brief Information

| | | |
|---|---|---|
| Organization's Name | : | Child Protection Unit of the Cambodian Children's Fund (CPU) |
| Type of organization | : | International Organization |
| Address | : | Land Lot #120, National Road 2, Battachi 1 Village, Sangkat Prek Ho, Krong Takhmao, Kandal Province |
| Contact phone | : | 077 247 257 |
| Email | : | info@childprotectionunit.org |
| Website | : | www.childprotectionunit.org |
| Project Title | : | Contribution to humanitarian and criminal justice activities for juveniles in the Kingdom of Cambodia |
| Project code | : | 24-CP144 |

Signed a Memorandum of Understanding with the Ministry of Foreign Affairs and International Cooperation on November 3, 2022

| | | |
|---|---|---|
| Project implementation location | : | 25 provinces-capital |
| Partner Organizations | : | Cambodian Children's Fund (CCF) |
| Project implementation budget | : | $ 4 million |
| Start date | : | |
| End date | : | |
| Number of Khmer employees | : | 77 people |
| Number of foreign employees | : | 03 people |

## Annex 2

### Humanitarian activities of the Child Protection Unit of the Cambodian Children's Fund

### 1. Collection and Provision of Secret Intelligence Information

Collaborate with the specialized department of the General Commissariat of National Police to collect evidence related to human trafficking, sexual abuse and child exploitation, cybercrime and other crimes committed by criminals in violation of the laws of the Kingdom of Cambodia.

Develop detailed reports and provide detailed evidence of criminal offenses related to child sexual abuse and exploitation, child trafficking, cybercrime and other crimes against children.

Provide detailed and reliable reports related to the level of crimes against children that occur in the Kingdom of Cambodia.

### 2. Intervention and Rescue

Cooperate in partnership with the National Police of Cambodia, aiming to rescue victims of human trafficking, sexual exploitation, sexual abuse and other exploitation of children, cybercrime and crimes against children, as well as ensuring the arrest of perpetrators and accomplices to be sent for court prosecution in accordance with the laws of the Kingdom of Cambodia.

Work closely with the Cambodian National Police to collect physical evidence related to human trafficking, sexual exploitation, sexual abuse and exploitation of children, cybercrime and other crimes against children.

Collaborate with the Cambodian National Police to ensure that the rights of all children who are victims of human trafficking, sexual abuse and exploitation, cybercrimes and other crimes against children are respected, and they are protected and provided with legal services during the trial proceedings of the accused.

### 3. Coordination of Post-Rescue Care

The victims will be coordinated and supported with respect and dignity. All victims will be assessed according to their immediate needs, located in an appropriate care agency and assigned to post-rescue care for their health care and rehabilitation. All victims will have a liaison officer appointed to assist them in the court proceeding.

### 4. Training of Cambodian National Police

The specialized and legal training will be provided to: the Anti-human Trafficking and Juvenile Protection Police Department, Technical and Scientific Police Department, Criminal Investigation Police Department and Anti-Cybercrime Department of the General Commissariat of National Police, Ministry of Interior, in investigating sexual abuse, other exploitation of children and other areas which these departments are considered necessary.

## Section 5
## Dispute Resolution

Any possible disputes regarding the interpretation or implementation of this Memorandum of Understanding shall be immediately resolved by the General Commissariat of National Police, the Ministry of Interior, and the Child Protection Unit of the Cambodian Children's Fund by means of peaceful negotiations through talking or other agreed methods.

## Section 6
## Effect and Validity

This Memorandum of Understanding is effective from the signing date and valid for 3 (Three) years and can be renewed with the consent of both parties.

## Section 7
## Final Provision

Either party may notify the other party in writing at any time if it intends to terminate this Memorandum. The Memorandum of Understanding will be terminated within 60 (sixty) days from the date of receipt of the notification.

This Memorandum of Understanding is made with two original copies, in Khmer and English language, with equal value in both languages, which is not an agreement for creating any rights or obligation at all. In case of any discrepancy on the interpretation of these two versions, the Khmer version shall prevail.

Phnom Penh, 12 May, 2026

| | |
|---|---|
| **On Behalf of Minister of Interior**<br>**Secretary of State** | **Representative of Child Protection Unit of Cambodian Children's Fund**<br>**Director in charge of operations** |
| **Chou Bun Eng** | **Jame McCabe** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CPU
CHILD PROTECTION
UNIT

# អនុស្សរណៈនៃការយោគយល់

រវាង

## ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា

និង

## អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា

ស្ដីពី

## ការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់អនីតិជននៅព្រះរាជាណាចក្រកម្ពុជា

ឆ្នាំ ២០២៦ - ២០២៩

## បុព្វកថា

**ដោយហេតុថា ÷**

- ក្រសួងមហាផ្ទៃ បានបង្ហាញនូវការគាំទ្ររបស់ខ្លួន ដែលស្តែងឡើងនៅក្នុងអនុស្សរណៈនៃការយោគយល់នេះ ដល់អង្គភាពការពារកុមារ(CPU)នៃអង្គការមូលនិធិកុមារកម្ពុជា ចូលរួមក្នុងសកម្មភាពមនុស្សធម៌ ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈតាមកិច្ចសហប្រតិបត្តិការទៅវិញ ទៅមក។
- ក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា (CPU) ទទួលស្គាល់ថាមានបទល្មើសច្រើនទម្រង់ពាក់ព័ន្ធអំពើជួញដូរមនុស្ស ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទកុមារដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ និងបទល្មើសផ្សេងទៀតដែលប្រព្រឹត្តចំពោះស្ត្រី និងកុមារ ។
- ដោយសារលក្ខណៈស្មុគស្មាញនៃបទល្មើសព្រហ្មទណ្ឌទាំងនេះ អាចមានភាពចាំបាច់ក្នុងការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតរបស់អ្នកឯកទេស ដែលរួមទាំងភ្នាក់ងារសម្ងាត់ផងដែរ ក្នុងគោលបំណងប្រមូលភស្តុតាង និងព័ត៌មានសម្ងាត់ ដើម្បីធ្វើការចោទប្រកាន់បទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចលើកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ និងបទល្មើសផ្សេងទៀតដែលប្រព្រឹត្តប្រឆាំងនឹងអនីតិជន តាមនីតិវិធីដែលមានជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។ ការប្រើប្រាស់ភ្នាក់ងារសម្ងាត់ គឺជាធនធានមួយដ៏ជោគជ័យ និងមានប្រសិទ្ធភាពដែលត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅទូទាំងពិភពលោក។
- ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើស្ត្រី និងកុមារ អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា (CPU) មានបំណងសហការផ្ទាល់ជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃដោយចូលរួមនៅក្នុងសកម្មភាពមនុស្សធម៌ដោយផ្ទាល់ដូចខាងក្រោម៖

## ប្រការ១

### គោលបំណង

អនុស្សរណៈនៃការយោគយល់នេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការ រវាងអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា(CPU) ដើម្បីរួមចំណែកក្នុងសកម្មភាពមនុស្សធម៌ និងពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការរួមចំណែកប្រមូល និងផ្តល់ព័ត៌មានធ្វើអន្តរាគមន៍ និងជួយសង្គ្រោះ សម្របសម្រួលថែទាំ កុមារក្រោយពេលសង្គ្រោះ និងការបណ្តុះបណ្តាល ពង្រឹងសមត្ថភាព នគរបាលជាតិកម្ពុជា ។

## ប្រការ២

## សកម្មភាពនៃកិច្ចសហប្រតិបត្តិការ ÷

### ១-ការប្រមូល និងការផ្តល់ព័ត៌មាន

- **អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** ត្រូវសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ដើម្បីចូលរួមផ្តល់ព័ត៌មានជាជំនួយលើការស៊ើបអង្កេត និងប្រមូលភស្តុតាងនានាពាក់ព័ន្ធ អំពើជួញដូរមនុស្សគ្រប់ទម្រង់ជាពិសេសស្ត្រី និងកុមារ ដោយធានាថា រាល់ភស្តុតាងនៃការប្រព្រឹត្តល្មើសច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរកឃើញ និងប្រមូលបាន ត្រូវផ្តល់ជូនអង្គភាពជំនាញពាក់ព័ន្ធដែលមានសមត្ថកិច្ច និងសហការអនុវត្តតាមនីតិវិធីជំនាញ។ រាល់នីតិវិធីប្រមូលព័ត៌មានសម្ងាត់នឹងត្រូវដាក់ស្នើ ដើម្បីសុំការឯកភាពពីនាយកដ្ឋានជំនាញពាក់ព័ន្ធ នៃអគ្គស្នងការដ្ឋាននគរបាលជាតិមុនពេលចាប់ផ្តើម ឬអនុវត្ត ។
- ត្រូវមានរបាយការណ៍ និងព័ត៌មានលម្អិតដែលប្រមូលបានជូន អគ្គស្នងការដ្ឋាននគរបាលជាតិតាមរយៈនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានពាក់ព័ន្ធ នូវសកម្មភាពល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសការរំលោភបំពានលើកុមារ ។
- ត្រូវបង្ហាញទីតាំងកំណត់អត្តសញ្ញាណបឋម និងរបាយការណ៍ស្តីពីជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសការរំលោភបំពានលើកុមារមកអគ្គស្នងការដ្ឋាននគរបាលជាតិតាមរយៈនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានពាក់ព័ន្ធ ។

### ២-ការធ្វើអន្តរាគមន៍ និងការសង្គ្រោះ

- **អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដើម្បីអន្តរាគមន៍ និងជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្សចេញពីទីកន្លែង ឬស្ថានភាពនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់ជាពិសេសការរំលោភបំពានលើកុមារ និងធ្វើឱ្យប្រាកដថាមានការចាប់ខ្លួនជនប្រព្រឹត្តបទល្មើសបញ្ជូនទៅអយ្យការអមសាលាដំបូងរាជធានី-ខេត្តដើម្បីផ្តន្ទាទោសតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។
- ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ និងសេវាបឋមជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសការរំលោភបំពានលើកុមារ។

### ៣-ការសម្របសម្រួលក្រោយពេលសង្គ្រោះ

- **អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** ត្រូវសហការដឹកជញ្ជូនជនរងគ្រោះចេញពីកន្លែងកើតហេតុ មកកាន់ទីតាំងដែលមានសន្តិសុខ និងមានសុវត្ថិភាព ដើម្បីធ្វើការសម្ភាស ប្រមូលព័ត៌មានដោយមន្ត្រីមានសមត្ថកិច្ច និងបន្ទាប់មកធ្វើការសហការជាមួយមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្តក្រោមគោលការណ៍ណែនាំ នៃអនុស្សរណៈនៃការយោគយល់រវាង **អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** និង ដើម្បីធ្វើការដឹកជញ្ជូន ជនរងគ្រោះពីនគរបាល

ជំនាញ ទៅកាន់មណ្ឌលថែទាំដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ឬធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍វិញ។

- ត្រូវសម្របសម្រួលជាមួយមន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ដូចជា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត ដើម្បីផ្តល់ការថែទាំ ជនរងគ្រោះ ដែលមានវិបត្តិ ជាពិសេសអនីតិជនបន្ទាប់ពីមានការជួយសង្គ្រោះភ្លាមៗ។
- ប្រតិបត្តិរាល់សកម្មភាពមនុស្សធម៌ជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគោលការណ៍នៃកិច្ចសហប្រតិបត្តិការឱ្យស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**៤-ការបណ្តុះបណ្តាលមន្ត្រីនគរបាល**

- **អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** ត្រូវសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ដើម្បីផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស ស្តីពីប្រធានបទផ្សេងៗតាមការព្រមព្រៀង នៃក្រុមការងារបច្ចេកទេស ដែលអាចនឹងរួមបញ្ចូលប្រធានបទដូចជាទិដ្ឋភាពទូទៅនៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ ការប្រមូលព័ត៌មានព្រហ្មទណ្ឌសម្ងាត់។

## ប្រការ៣

## ការទទួលខុសត្រូវរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ

- អនុញ្ញាតឱ្យអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា (CPU) សហការគាំទ្រដល់នាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ក្នុងការបង្កើតគម្រោងស៊ើបអង្កេតទៅលើអ្នកជួញដូរមនុស្ស ជនដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ជនល្មើសដែលពាក់ព័ន្ធនឹងការរំលោភបំពាន ការកេងប្រវ័ញ្ចផ្សេងៗលើកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ បទល្មើសផ្សេងទៀតដែលប្រព្រឹត្តប្រឆាំងនឹងកុមារ និងអំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ដែលបំពានអំណាចរបស់ខ្លួន ទៅលើជនរងគ្រោះ។ ក្រោយពេលទទួលភស្តុតាងដែលអាចទុកចិត្ត និងអាចជឿជាក់បានពីអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា អគ្គស្នងការដ្ឋាននគរបាលជាតិបញ្ជាដឹកនាំភ្លាម ឱ្យមានការស៊ើបអង្កេតបន្ថែម ដោយអនុវត្តទៅតាមនីតិវិធីជំនាញ ដើម្បីធ្វើការបង្ក្រាបបទល្មើស និងធ្វើការឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីផ្តន្ទាទោសទៅតាមផ្លូវច្បាប់ ។
- យល់ព្រមថាការប្រមូលព័ត៌មាន និងភស្តុតាងពាក់ព័ន្ធការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ និងបទល្មើសផ្សេងទៀត ត្រូវអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។
- អនុញ្ញាតឱ្យអគ្គស្នងការដ្ឋាននគរបាលជាតិ ឯកភាពចំពោះគម្រោងរបស់អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា ក្នុងការគាំទ្រដល់ការបណ្តុះបណ្តាលនគរបាលជំនាញ និងការពង្រឹងសមត្ថភាព

នគរបាលជាតិ។ គម្រោងនៃការបណ្តុះបណ្តាលទាំងអស់នេះ នឹងត្រូវបានឯកភាពដោយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃជាមុន។

## ប្រការ៤

## ការទទួលខុសត្រូវរបស់អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា

- គោរពតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួនចូលរួម ឬធ្វើសកម្មភាពណាមួយផ្ទុយពីច្បាប់ ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ប្រជាជនកម្ពុជាឡើយ ។
- ត្រូវចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ដែលទទួលបានការអនុញ្ញាតពី**ក្រសួងមហាផ្ទៃ** ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈ និងជៀសវាងដាច់ខាតពីការពាក់ព័ន្ធនឹងសកម្មភាពបង្កើតប្រាក់ចំណូល និងសកម្មភាពនយោបាយដែលមិនបម្រើដល់គោលដៅមនុស្សធម៌របស់**អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** ដែលបានប្រកាស ។
- ត្រូវប្រតិបត្តិរាល់សកម្មភាព និងអនុវត្តកម្មវិធីគម្រោងមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជាក្នុងក្របខ័ណ្ឌនៃធនធានបុគ្គលិក និងមូលនិធិរបស់ខ្លួន ព្រមទាំងធានាឱ្យបានថា រាល់ការទទួលបានព័ត៌មាន ឬភស្តុតាងនៃការបំពានច្បាប់កម្ពុជា ដែលខ្លួនបានប្រមូលនឹងត្រូវបញ្ជូនទៅនគរបាលមានសមត្ថកិច្ច សម្រាប់ចាត់វិធានការបន្ត ។
- រាល់ការចុះប្រមូលព័ត៌មាន **អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** ត្រូវតែផ្តល់របាយការណ៍ជូនទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានជំនាញពាក់ព័ន្ធ។ រាល់នីតិវិធីនៃការប្រមូលព័ត៌មាន ត្រូវមានរបាយការណ៍ ដោយមានការឯកភាពគ្នាជាមុន ។
- មិនអនុញ្ញាតឱ្យចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងការស្វែងរកផលប្រយោជន៍ និងធ្វើសកម្មភាពនយោបាយណាមួយ ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។
- ធ្វើរបាយការណ៍ឆមាស និងឆ្នាំស្តីពីសមិទ្ធផល ក៏ដូចជាបញ្ហាប្រឈមនានាដែលបានជួបប្រទះ ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដើម្បីជ្រាប និងដោះស្រាយ។
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និងនាយកគម្រោងដែលបានចាត់តាំង។
- សេចក្តីសង្ខេបអំពីគម្រោង និងសកម្មភាពមនុស្សធម៌ជាក់ស្តែងរបស់អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជាសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ត្រូវប្រតិបត្តិដូចមានចែងលម្អិតក្នុងឧបសម្ព័ន្ធ(១) និង(២)។

# ឧបសម្ព័ន្ធ១

## ព័ត៌មានសង្ខេប

| | | |
|---|---|---|
| ឈ្មោះអង្គការ | ៖ | អង្គភាពការពារកុមារ នៃអង្គការមូលនិធិកុមារកម្ពុជា (CPU) |
| ប្រភេទអង្គការ | ៖ | អង្គការអន្តរជាតិ |
| អាសយដ្ឋាន | ៖ | ក្បាលដីលេខ១២០ ផ្លូវជាតិលេខ២ ភូមិបត្តាដី១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល |
| លេខទូរស័ព្ទទំនាក់ទំនង | ៖ | ០៧៧ ២៤៧ ២៥៧ |
| អ៊ីម៉ែល | ៖ | www.childprotectionunit.org |
| ឈ្មោះគម្រោង | ៖ | ការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជននៅព្រះរាជាណាចក្រកម្ពុជា |
| លេខកូដគម្រោង | ៖ | 24-CPU144 |

បានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០២២

| | | |
|---|---|---|
| ទីតាំងអនុវត្តគម្រោង | ៖ | ២៥ ខេត្ត-រាជធានី |
| អង្គការដៃគូ | ៖ | អង្គការមូលនិធិកុមារកម្ពុជា CCF |
| ថវិកាអនុវត្តគម្រោង | ៖ | ៤,000,000 USD (បួនលានដុល្លារអាម៉េរិកគត់) |
| កាលបរិច្ឆេទចាប់ផ្ដើម | ៖ | ថ្ងៃទី ខែ ឆ្នាំ២០២៦ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ថ្ងៃទី ខែ ឆ្នាំ២០២៩ |
| ចំនួនបុគ្គលិកខ្មែរ | ៖ | ៧៧ នាក់ |
| ចំនួនបុគ្គលិកបរទេស | ៖ | ៣ នាក់ |

## ឧបសម្ព័ន្ធ២

## សមត្ថភាពមនុស្សធម៌របស់អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា (CPU)

**១. ការប្រមូល និងផ្ដល់ព័ត៌មានសម្ងាត់**

- ត្រូវសហការជាមួយនាយកដ្ឋានជំនាញនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីប្រមូលភស្តុតាងពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចលើកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ និងបទឧក្រិដ្ឋផ្សេងទៀតដែលប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជនបំពានលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

- ធ្វើរបាយការណ៍លម្អិត និងផ្ដល់ភស្តុតាងលម្អិតអំពីបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចលើកុមារ អំពើជួញដូរកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ និងបទឧក្រិដ្ឋផ្សេងទៀត ដែលប្រព្រឹត្តប្រឆាំងនឹងកុមារ ។

- ផ្ដល់របាយការណ៍លម្អិត និងគួរទុកចិត្តបាន ពាក់ព័ន្ធនឹងកម្រិតបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងកុមារដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**២. ការធ្វើអន្តរាគមន៍ និងការជួយសង្គ្រោះ**

- សហការជាដៃគូជាមួយនគរបាលជាតិកម្ពុជាក្នុងគោលបំណង ជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្សេងទៀតលើកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ និងបទឧក្រិដ្ឋដែលប្រព្រឹត្តប្រឆាំងនឹងកុមារ ព្រមទាំងធានាដល់ការឃាត់ខ្លួនចារី និងអ្នកពាក់ព័ន្ធបញ្ជូនទៅអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីផ្ដន្ទាទោសទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

- សហការយ៉ាងជិតស្និទ្ធជាមួយនគរបាលជាតិកម្ពុជា ដើម្បីប្រមូលភស្តុតាងរូបវន្ត ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចលើកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ និងបទឧក្រិដ្ឋផ្សេងទៀតដែលប្រព្រឹត្តប្រឆាំងនឹងកុមារ ។

- សហការជាមួយនគរបាលជាតិកម្ពុជា ដើម្បីធានាថា សិទ្ធិរបស់កុមារគ្រប់រូបដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចលើកុមារ បទល្មើសតាមប្រព័ន្ធអនឡាញ និងបទឧក្រិដ្ឋផ្សេងទៀត ដែលប្រព្រឹត្តប្រឆាំងនឹងកុមារ ត្រូវបានគោរព ហើយពួកគេទទួលបាននូវកិច្ចគាំពារ និងផ្ដល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះក្នុងអំឡុងដំណើរការនីតិវិធីតុលាការនៃការកាត់ទោសជនជាប់ចោទ ។

**៣. ការសម្របសម្រួល ការថែទាំក្រោយពេលសង្គ្រោះ**

ជនរងគ្រោះនឹងត្រូវទទួលបានការសម្របសម្រួល និងគាំពារដោយការគោរព និងសេចក្ដីថ្លៃថ្នូរ។ ជនរងគ្រោះគ្រប់រូបនឹងត្រូវបានវាយតម្លៃទៅតាមតម្រូវការភ្លាមៗរបស់ពួកគេរួមមាន៖ ទីតាំងភ្នាក់ងារថែទាំយ៉ាងសមស្រប និងត្រូវបានបែងចែកសម្រាប់ការថែទាំក្រោយពេលសង្គ្រោះពួកគេសម្រាប់ការថែទាំសុខភាព និងការស្ដារនីតិសម្បទា។ ជនរងគ្រោះគ្រប់រូបនឹងមានមន្ត្រីទំនាក់ទំនងដែលត្រូវបានតែងតាំងមួយរូប ដើម្បីជួយពួកគេក្នុងដំណើរការរឿងក្ដីទៅតុលាការ ។

**៤. ការបណ្ដុះបណ្ដាលនគរបាលជាតិកម្ពុជា**

ការបណ្ដុះបណ្ដាលអ្នកឯកទេសជំនាញ និងច្បាប់នឹងត្រូវបានផ្ដល់ជូននគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ក្នុងការស៊ើបអង្កេតអំពីការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្សេងទៀត លើកុមារ និងផ្នែកផ្សេងទៀត ដែលនាយកដ្ឋានទាំងនេះចាត់ទុកថាមានភាពចាំបាច់ ។

## ប្រការ៥

### ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តអនុស្សរណៈនេះត្រូវដោះស្រាយជាបន្ទាន់ដោយសន្តិវិធីតាមរយៈការពិគ្រោះយោបល់ ឬតាមមធ្យោបាយផ្សេងទៀតដែលបានព្រមព្រៀង ។

## ប្រការ៦

### ការចូលជាធរមាន និងសុពលភាព

អនុស្សរណៈនេះ ចូលជាធរមានចាប់ពីពេលចុះហត្ថលេខាដោយគូភាគី ។

អនុស្សរណៈនេះ មានសុពលភាពរយៈពេល ០៣(បី)ឆ្នាំ ហើយនឹងអាចបន្តសុពលភាពបានទៀត ដោយមានការយល់ព្រមពីគូភាគី ។

## ប្រការ៧

### ការបញ្ចប់

អនុស្សរណៈនេះ អាចបញ្ចប់បានដោយភាគីណាមួយក៏បាន ដោយការជូនដំណឹងអំពីបំណងបញ្ចប់ការអនុវត្តអនុស្សរណៈនេះ ជូនភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ អនុស្សរណៈនេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង ។

អនុស្សរណៈយោគយល់នេះ ត្រូវធ្វើឡើងចំនួន ០២(ពីរ) ច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរនេះមានតម្លៃស្មើគ្នា ដែលពុំមែនជាកិច្ចព្រមព្រៀងបង្កើតសិទ្ធិ និងកាតព្វកិច្ចណាមួយឡើយ។ ក្នុងករណីមានការបកស្រាយខុសគ្នា វិវាទ ឬចំណុចមិនស្របគ្នា គូភាគីត្រូវយកអត្ថបទភាសាខ្មែរជាគោល ។

ថ្ងៃសុក្រ ១១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៦

| | |
|---|---|
| **ក្រសួងមហាផ្ទៃ** | **តំណាងអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា** |
| **រដ្ឋលេខាធិការ** | **នាយកទទួលបន្ទុកប្រតិបត្តិការ** |
| **ជូ ប៊ុនអេង** | **ជេមស៍ ម៉ាកខេប** |